ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**នាយកដ្ឋានព័ត៌មាន**

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា និងរុស្ស៊ី នឹងរៀបចំកិច្ចប្រជុំលើកទី១១ នៃគណៈកម្មការអន្តររដ្ឋាភិបាល ស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស

**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** Oksana Lut រដ្ឋមន្ត្រីកសិកម្មនៃសហព័ន្ធរុស្ស៊ី នឹងធ្វើជាសហប្រធានកិច្ចប្រជុំលើកទី១១ នៃគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស (11th IGC) នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ តាមប្រព័ន្ធវីដេអូ។

កិច្ចប្រជុំ 11th IGC នឹងពិនិត្យមើលវឌ្ឍនភាព ដែលសម្រេចបានក្នុងភាពជាដៃគូសហប្រតិបត្តិការរួម រវាងកម្ពុជា និងរុស្ស៊ី នារយៈពេលកន្លងមកនេះ ព្រមទាំងកំណត់ទិសដៅនៅពេលអនាគត ដើម្បីជំរុញបន្ថែមទៀតនូវទំនាក់ទំនងដ៏យូរលង់រវាងប្រទេសទាំងពីរ។ ភាគីទាំងពីរនឹងធ្វើការពិភាក្សាយ៉ាងស៊ីជម្រៅ ក្នុងការរិះរកវិធីដើម្បីជំរុញ និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងរវាងប្រទេសទាំងពីរ លើវិស័យផ្សេងៗ រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ថ្ងៃអាទិត្យ ១កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh